ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៧៦
ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១
សាលដីកា
លេខ ២៧៨ "VIII"
ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២

# សាលដីកា
# តាងនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ជាប្រធាន

២.ឯកឧត្តម [redacted] ជាចៅក្រម

៣.ឯកឧត្តម [redacted] ជាចៅក្រមរបាយការណ៍

៤.ឯកឧត្តម [redacted] ជាចៅក្រម

៥.ឯកឧត្តម [redacted] ជាចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្ដឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ០២៦/៩ ព្រទ.ក្រII ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ព្រះសីហនុ ដែលមាន៖

- ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៥២ឆ្នាំ កើតឆ្នាំ១៩៦០ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កម្មករសំណង់ មានទីកន្លែងកំណើតនៅភូមិក្រាំ [redacted] ទីលំនៅមុនពេលឃុំខ្លួននៅភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៥នាក់ ទោសពីមុនគ្មាន ។ (អ្នកប្ដឹងសាទុក្ខ)



Scanned with CamScanner

.ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៣២៦៧ តចឃ/២០ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០ នៅពន្ធនាគារ ខេត្តព្រះសីហនុ

ជាប់ចោទពីបទ **រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ** ប្រព្រឹត្តនៅភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៩ ដល់អំឡុងខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

មានលោក[redacted] ម៉ូរ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ជនរងគ្រោះឈ្មោះ [redacted] ចន្ធី ភេទស្រី អាយុ ១៣ឆ្នាំ ជនជាតិខ្មែរ [redacted]។

មានលោកស្រី [redacted]សារាទី ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ។

**អំពីអង្គហេតុ**

កាលពីថ្ងៃ០៩ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ០៩ព្រឹក ស្ថិតនៅភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ជនសង្ស័យឈ្មោះ [redacted] វ៉ន បានរួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted] ចន្ធី ភេទស្រី អាយុ១៣ឆ្នាំ ដែលបានស្នាក់នៅជាមួយ។ ក្រោយមកជនរងគ្រោះបានប្រាប់រឿងរ៉ាវទៅកាន់ជីដូនឈ្មោះ [redacted]សុភាព ដោយប្រាប់ទៀតថា ជនសង្ស័យបានសន្យាជាមួយខ្លួនថានឹងទិញម៉ូតូមកឱ្យ។ បន្ទាប់ពីឮដំណឹងនេះ ឈ្មោះ [redacted]សុភាព បានសួរនាំឈ្មោះ [redacted] វ៉ន អំពីរឿងរ៉ាវទាំងនោះបណ្តាលឱ្យឈ្មោះប្រកែកគ្នា និងបណ្តេញឈ្មោះ [redacted] វ៉ន ចេញពីផ្ទះ។ រហូតដល់អំឡុងខែមីនា ឆ្នាំ២០២០ ជនរងគ្រោះឈ្មោះ [redacted] ចន្ធី បានប្រាប់ឈ្មោះ [redacted]សុភាព ថា ឈ្មោះ [redacted] វ៉ន បានមកសុំខ្លួនរួមភេទទៀត និងបានទិញទូរស័ព្ទដៃ ០១គ្រឿងឱ្យទៅជនរងគ្រោះ ក្រោយពីសួរនាំជនរងគ្រោះ ទើបដឹងថាឈ្មោះ [redacted] វ៉ន ធ្លាប់បានលួងលោមរួមភេទជាមួយជនរងគ្រោះជាច្រើនដងបានសម្រេច។

- **បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ១០១១/១០៦ (ឈ) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

ផ្តន្ទាទោសឈ្មោះ [redacted] វ៉ន ភេទប្រុស អាយុ ៥២ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ០៥ (ប្រាំ)ឆ្នាំ ពីបទ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅភូមិចំណោទរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០១៩ ដល់អំឡុងខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។



Scanned with CamScanner

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃចន្ទ ៣រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃអង្គារ ១១កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]ន។

ទុកសិទ្ធិឱ្យប្ដឹងឧទ្ធរណ៍នៅក្នុងកំណត់ច្បាប់។

- **បានឃើញ** បណ្ដឹងឧទ្ធរណ៍លេខ ១៨៧ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] វ៉ន ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១០១១/១០៦ (ឈ) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

- **បានឃើញ** សាលដីកាព្រហ្មទណ្ឌលេខ ០២៦/៩ ព្រទ.ក្រII ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ ១៨៧ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ [redacted] វ៉ន ទុកជាត្រឹមត្រូវតាមតម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១០១១/១០៦ (ឈ) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការពេញទាំងមូល។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី។

៤-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ, កំបាំងមុខជនរងគ្រោះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១។

បើកសិទ្ធិប្ដឹងទាស់ និងប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

- **បានឃើញ** បណ្ដឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] វ៉ន ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ០២៦/៩ ព្រទ.ក្រII ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ព្រះសីហនុ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ជនជាប់ចោទពុំបានដាក់សារណាការពារជូនតុលាការកំពូលទេ ដូច្នេះ ពុំមានមូលហេតុពិចារណាលើបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទនោះទេ ស្របតាមមាត្រា ៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សាលដីកាព្រហ្មទណ្ឌលេខ ០២៦/៩ ព្រទ.ក្រII



Scanned with CamScanner

ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ព្រះសីហនុ សម្រេចត្រឹមត្រូវតាមច្បាប់ហើយ ដូច្នេះ សុំក្រុមប្រឹក្សាជំនុំជម្រះតម្កល់សាលដីកានេះ ទុកជាបានការដដែល។

+ជនជាប់ចោទឈ្មោះ [redacted] ម៉ែន បានឆ្លើយថា៖ ដើមបណ្តឹងរដ្ឋប្បវេណីបានដកពាក្យបណ្តឹងហើយ ខ្លួនប្តឹងសាទុក្ខមកនេះ ដើម្បីសុំឱ្យតុលាការកំពូលមេត្តាពិចារណា ជួយដោះលែងខ្លួនឱ្យមានសេរីភាពវិញ។

+លោក [redacted] ម្វ៉ា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្លួនបានសារភាពរួចថា ប្រពន្ធរបស់គាត់បានដកពាក្យបណ្តឹងហើយ ដោយសារពេលដែលប្តីជាប់ពន្ធនាគារ គ្មានអ្នកជួយផ្គត់ផ្គង់ជីវភាពគ្រួសារ ដែលមានសមាជិក ៧-៨នាក់ ថែមទាំងជំពាក់បំណុលធនាគារទៀត ជនជាប់ចោទក៏បានទទួលស្គាល់កំហុសរួចហើយដែរ។ តាមក្រមព្រហ្មទណ្ឌជនជាប់ចោទមានសិទ្ធិស្នើសុំការព្យួរទោសពី ៥ឆ្នាំចុះក្រោមបាន មិនបង្កការលំបាកដល់ចំណាត់ការរបស់តុលាការនោះទេ។ ជនជាប់ចោទមានវ័យចាស់ និងមានជម្ងឺ គាត់ចង់ចេញពីពន្ធនាគារជួបជុំគ្រួសារវិញ។

សំណូមពរ សូមតុលាការសម្រេចបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍វិញដើម្បីជំនុំជម្រះជាថ្មី។

+លោកស្រី [redacted] ណរាទី ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះបានធ្វើសេចក្តីសន្និដ្ឋានថា៖ ជនជាប់ចោទបានឆ្លើយសារភាពនៅចំពោះមុខអង្គសវនាការ ក៏ដូចជានៅគ្រប់ដំណាក់កាលផងដែរ ហើយជនរងគ្រោះទៀតសោតក៏បានឆ្លើយថា ជីតាគាត់ពិតជាបានរំលោភគាត់ពិតមែន។ សំបុត្រកំណើតក៏បានបញ្ជាក់ដែរថា កូនក្តីខ្លួនបានកើតនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧ បើគិតពីថ្ងៃប្រព្រឹត្តរបស់ជនជាប់ចោទនៅក្នុងខែឧសភា ឆ្នាំ២០១៩ ក្នុងអំឡុងពេលជនរងគ្រោះមានអាយុ១២ឆ្នាំ ពិតប្រាកដមែន ដូច្នេះ សូមតុលាការពិចារណាលើចំណុចនេះ។ ផ្អែកលើចម្លើយជនជាប់ចោទ និងចម្លើយជនរងគ្រោះគឺករណីរួមភេទជាមួយអនីតិជនក្រោមអាយុ១៥ឆ្នាំ អំឡុងខែមីនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីបង្ក្រាបអំពើជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទពិតប្រាកដមែន។

សំណូមពរ សូមតុលាការសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០២៦/៩ ព្រទ.ក្រII ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ព្រះសីហនុ ទុកជាបានការ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនរងគ្រោះ



Scanned with CamScanner

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

១. យល់ឃើញថា បណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]វិន ធ្វើឡើងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. យល់ឃើញថា នាពេលសវនាការជនជាប់ចោទ ក៏ដូចជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វិន បានធ្វើសេចក្តីសន្និដ្ឋានសុំឱ្យតុលាការកំពូល ពិនិត្យសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួន ដោយសំអាង អ្នកប្តឹងកូនក្តីខ្លួនបានដកពាក្យបណ្តឹងវិញហើយៗស្ថានភាពគ្រួសារមានភាពលំបាក មានបំណុលជំពាក់ធនាគារ លើសពីនេះទៅទៀត នៅក្នុងនីតិវិធីរបស់តុលាការ កូនក្តីខ្លួនបានទទួលស្គាល់កំហុសរបស់ខ្លួនដែលបានប្រព្រឹត្តការរួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted] ចន្ធី ពិតប្រាកដមែន មិនបង្កការលំបាកដល់ចំណាត់ការរបស់តុលាការនោះទេ នោះតុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះថា តុលាការកំពូលជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី១របស់ជនជាប់ចោទ គឺតុលាការកំពូលពិនិត្យមើលលើអង្គច្បាប់តែប៉ុណ្ណោះ ហើយបើពិនិត្យមើលសេចក្តីសម្រេចនៃសាលដីកាព្រហ្មទណ្ឌលេខ ០២៦/៩ ព្រទ.ក្រII ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ព្រះសីហនុ តុលាការកំពូលពិនិត្យឃើញថា មានអង្គហេតុ និងអង្គច្បាប់ត្រឹមត្រូវហើយ។ ហេតុដូច្នេះ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទខាងលើ ពុំមានមូលហេតុសមស្របតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ។

៣. យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ០២៦/៩ ព្រទ.ក្រII ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ព្រះសីហនុ ដែលបានសម្រេចមកនេះ ត្រឹមត្រូវតាមគតិច្បាប់។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១. បដិសេធបណ្តឹងសាទុក្ខលេខ ០៥ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted]វិន ។

២. តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០២៦/៩ ព្រទ.ក្រII ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ព្រះសីហនុ ទុកជាបានការពេញទាំងមូល ។



Scanned with CamScanner

៣. សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសនាពេលសវនាការជាសាធារណៈ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ។

ឯកឧត្តម [redacted] ជាប្រធាន

ឯកឧត្តម [redacted] ជាចៅក្រម

ឯកឧត្តម [redacted] ជាចៅក្រម

ឯកឧត្តម [redacted] ជាចៅក្រម

ឯកឧត្តម [redacted] ជាចៅក្រម

លោកស្រី [redacted] ជាក្រឡាបញ្ជី

---

បានចម្លងត្រឹមត្រូវតាមសាលដីកាដើម ។

ថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner